# មហាជ័យជំនះយួន



សេរីការ

## មហាជ័យជំនះយួន

សេចក្ដីសង្ឃឹមលើការបោះឆ្នោតនៅក្នុងបរិបទខ្មែរសព្វថ្ងៃ ជាការទទួលស្គាល់មហាជ័យជំនះយួននៅស្រុកខ្មែរ ព្រោះខ្មែរយើងនាំគ្នាទទួលស្គាល់របបផ្ដាច់ការ ដែលមានយួន ជា អ្នកដឹកនាំ ជា អកុសលអាចទទួលយកបាន។ សេចក្ដីសង្ឃឹមនេះ ជា ឧន្នាគ៌ា[1] សំរាប់ប្រជាជាតិខ្មែរ ព្រោះជាចាគប័ត្រ[2] នៅក្នុងអារម្មណ៍អនានុភាព គឺថា ដឹងច្បាស់ថាវានឹងនាំមកនូវមហាទុក្ខដល់ជាតិ តែគ្មានដំណោះស្រាយផ្សេងមួយទៀត ក្រៅពីទទួលស្គាល់ជាតុណ្ហី[3] នៃមហាជោគជ័យយួនតែប៉ុណ្ណោះ។ បក្សប្រឆាំងនៅឆ្នាំ២០១៤ សំរេចចូលជាសមាជិកក្នុងសភា ដោយមានសេចក្ដីសំអាងថានឹងអាចធ្វើអោយ លទ្ធិប្រជាធិបតេយ្យ ដើរទៅមុខអោយជាតិមានការរីកចំរើន និង កំណែទំរង់ច្បាប់បោះឆ្នោតដើម្បីអោយការបោះឆ្នោតសមតាមសមធម៌ និងមានយុត្តិធម៌។ តែថ្លៃ ដែលបក្សប្រឆាំងបេះ គឺវាមានរស់ជាតិ ជា ផលាក្រពុលសំរាប់ប្រជាជាតិខ្មែរទៅវិញ មិនតែប៉ុណ្ណោះ ពួកអ្នកដឹងនាំបក្សប្រឆាំង កំពុងស៊ុមក្រលុំជាមួយបក្សកាន់អំណាចផ្ដាច់

---

1 ឧន្នាគ៌ា; Chemin du mal។

2 ចាគប័ត្រ; Résignation; ករលះបង់សិទ្ធិអោយអ្នកណាម្នាក់, ការអត់ធ្មត់ទ្រាំទ្រ។

3 តុណ្ហី; Tacite; ដោយកាត់យល់, ដែលស្ងៀម, តុណ្ហីភាព។

# មហាជ័យជំនះយួន

ការ អោយខ្មែរបរិភោគផ្លែក្រពុលនោះឯង។ យើងឃើញថ្មីៗនេះ ទូរទស្សន៍ជាតិ គេផ្សាយ សំនួរ និង ចម្លើយ នៅរដ្ឋសភា រវាង បក្សប្រឆាំង ជាមួយ រាជរដ្ឋាភិបាល ដើម្បីបង្ហាញអោយឃើញ ថានៅស្រុកខ្មែរ មានអនុវត្ត លទ្ធិប្រជាធិបតេយ្យ មានសេរីភាពនយោបាយ ព្រោះបក្សប្រឆាំង មានលទ្ធិភាពត្រួតពិនិត្យ សកម្មភាពនៃរដ្ឋាភិបាល។ សួរថា ចុះហេតុអ្វីបានជាអ្នកដឹកនាំ បក្សប្រឆាំងសុញ្ញគំនិត ធ្លាក់ទៅក្នុងកញ្ជោតភាពបែបនេះ ? យួនអង្គុយមើលទូរទស្សន៍ នាំគ្នាសើច ឃើញ លោក តំណាងរាស្ត្របក្សប្រឆាំងចោទសួរ ប្រកបដោយសុរោហារ ដល់រដ្ឋមន្ត្រីខ្វះ សមត្ថភាព ដូចដៃគូអ្នកច្រៀងអាយ៉ៃ ព្រោះអ្នកសួរ ភ្លេចគិត ថាមេបក្សរបស់ខ្លួនទាំងពីរ កំពុងរស់នៅក្នុងការឃុំឃាំងដោយ ខ្លួនឯង មួយនៅបរទេស មួយទៀតនៅទីស្តីការនៃគណបក្ស ហើយ មិត្តខ្លួនមួយចំនួនទៀត រស់នៅក្នុងគុកព្រៃស។ សេរីភាពក្នុងស៊ុម[4] នេះ តើពួកអ្នកដឹកនាំគណបក្សប្រឆាំង នៅក្នុងសតិរបស់គាត់ គាត់ទុកជាសេរីភាព ប្រកបដោយ មោទនភាពនោះឬ ? បើការវិលត្រឡប់ចូលរដ្ឋសភាវិញ ដើម្បីបំពេញ សិទ្ធិ ត្រឹមអាចកោះហៅរដ្ឋមន្ត្រីមកចោទសួរតែប៉ុណ្ណោះ វាគ្មាន ខ្លឹមសារអ្វីដល់ប្រយោជន៍ជាតិនោះឡើយ ព្រោះ សិទ្ធិក្នុងស៊ុម នេះ វានៅក្នុងមហាជ័យជំនះយួន គេបើកអោយប្រើសំរាប់តែ លាងដៃប្រឡាក់ឈាម នៃពួកជនផ្តាច់ការតែប៉ុណ្ណោះ។

---

[4] សេរីភាពក្នុងស៊ុម; liberté cadrée។